**(Insert school details)**

## *ចៃក្បាលវិលមកវិញហើយ ……*

ជំរាបមកដល់មាតាបិតា / អាណាព្យាបាល / អ្នកថែទាំ

ខ្ញុំបានកត់សំគាល់ឃើញថា សិស្សខ្លះនៅសាលារៀន អាចមានចៃក្បាល ហើយខ្ញុំសូមស្វែងរកកិច្ចសហការរបស់លោកអ្នក ក្នុងការឆែកមើលសក់របស់កូនលោកអ្នកនៅអាទិត្យនេះ (insert date __/__/__ to __/__/__) ។

ចៃក្បាលមិនមែនជាជំងឺឆ្លងមេរោគទេ ប៉ុន្តែវាអាចចម្លងតាមរយៈការប៉ះក្បាលជាមួយនឹងអ្នកណាមួយដែលមានចៃក្បាល។ លោកអ្នកអាចទទួលការធានាក្នុងការដឹងថា ជាធម្មតា គេរកឃើញចៃក្បាលនៅទីកន្លែងផ្សេងទៀត ក្រៅអំពី (insert name of school) ។ ចៃក្បាលកើតមានជាធម្មតាចំពោះក្មេងមានអាយុទៅសាលារៀន ហើយជាសត្វដែលប្រសប់បំផុតក្នុងការប្រែប្រួលខ្លួនវាទៅតាមស្ថានការណ៍នានា។ សត្វចៃនេះមានជីវិតរស់នៅដោយអាស្រ័យលើមនុស្សយើង អស់ពេល 10 000 ឆ្នាំ!!!!

<u>តើខ្ញុំអាចធ្វើអ្វីបាន?</u>

ខ្ញុំសូមស្វែងរកកិច្ចសហការរបស់លោកអ្នកក្នុងការឆែកមើលសក់របស់កូនលោកអ្នក និងដាក់ថ្នាំកំចាត់ចៃនៅលើសក់របស់កូនលោកអ្នក នៅក្នុងពេលដែលរកឃើញចៃឬពងចៃ។

សូមអានប័ណ្ណព័ត៌មានភ្ជាប់ជាមួយនេះ *ការព្យាបាលនិងការគ្រប់គ្រងចៃក្បាល* ពី Department of Human Services ។ ប័ណ្ណព័ត៌មាននេះមានសេចក្តីណែនាំជាដំណឹងអំពីការតាមរកមើលនិងការព្យាបាលកំចាត់ចៃក្បាលនិងពងចៃ។

<u>តើខ្ញុំព្យាបាលកំចាត់ចៃក្បាលចេញពីកូនខ្ញុំតាមរបៀបណា?</u>

ប័ណ្ណព័ត៌មានភ្ជាប់ជាមួយនេះ (ដូចដែលបានបញ្ជាក់នៅខាងលើ) មានសេចក្តីណែនាំជាដំណឹង អំពីការតាមពិនិត្យមើលនិងការព្យាបាលកំចាត់ចៃក្បាលនិងពងចៃ។ សាលាក៏មានព័ត៌មានបន្ថែមអំពីការព្យាបាលនិងការគ្រប់គ្រងចៃក្បាលផងដែរ។ សូមកុំស្ទាក់ស្ទើរក្នុងការទាក់ទង (insert relevant person) តាមទូរស័ព្ទលេខ (insert phone number) ដើម្បីទទួលព័ត៌មាននេះ។

<u>បើរកឃើញចៃក្បាលឬពងចៃនៅលើសក់របស់កូនលោកអ្នក លោកអ្នកត្រូវប្រាប់:</u>

- សាលារៀន ហើយប្រាប់ពេលដែលការព្យាបាលកំចាត់ចៃបានចាប់ផ្តើម តាមរយៈការបំពេញក្នុងក្រដាសបំពេញ*សកម្មភាពដែលបានធ្វើឡើង* ភ្ជាប់មកជាមួយនេះ។
- មាតាបិតាឬអ្នកថែទាំនៃមិត្តភក្តិរបស់កូនលោកអ្នក ដើម្បីឲ្យអ្នកទាំងនោះមានឱកាសតាមរកមើលនិងព្យាបាលកំចាត់ចៃក្បាលរបស់កូនខ្លួនផងដែរ បើសិនជាចាំបាច់។

<u>ពេលណាទៅដែលកូនខ្ញុំអាចវិលទៅសាលារៀនវិញ?</u>

បទបញ្ញត្តិសុខភាពតម្រូវថា នៅពេលដែលកុមារមានចៃក្បាល កុមារនោះមិនគួរវិលទៅកាន់សាលារៀនវិញឡើយ រហូតទាល់តែនៅថ្ងៃបន្ទាប់ពីការព្យាបាលសមរម្យបានចាប់ផ្តើមឡើង។ សូមកត់សំគាល់ថា ហេតុការណ៍នេះយោងសំដៅទៅកាន់កុមារដែលមានចៃរស់តែប៉ុណ្ណោះ ហើយមិនយោងសំដៅទៅកាន់ពងចៃនោះទេ។

(insert name of school) ដឹងថា ចៃក្បាលគឺជាបញ្ហាលំបាកមួយ ហើយមានការប្តូរផ្តាច់ក្នុងការរក្សាភាពសម្ងាត់របស់លោកអ្នក។

ដោយសេចក្តីគោរពស្មោះស្ម័គ្រ

Signature of Principal (or relevant other)

ថ្ងៃទី……………………